ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០០៣...ឧស...ឋ.ល..

# បទបញ្ជាផ្ទៃក្នុងរបស់មណ្ឌលប្រឡង

ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងវិន័យក្នុងការប្រឡង បេក្ខជនទាំងអស់ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌលប្រឡង ដែលមានចែងដូចខាងក្រោម៖

- បេក្ខជនត្រូវពិនិត្យឈ្មោះរបស់ខ្លួន ដែលមានបិទនៅមុខបន្ទប់ប្រឡងដើម្បីដឹងអំពីបន្ទប់ និងលេខតុដែលត្រូវប្រឡង ឲ្យបានរួចរាល់មុនរយៈពេល ៣០នាទី មុនការហៅឈ្មោះចូលតាមបន្ទប់ប្រឡង។
- មិនត្រូវយកសំណៅឯកសារ អាវុធ ឬជាតិផ្ទុះ ទូរស័ព្ទដៃ អាយផូន អាយផេត កុំព្យូទ័រយួរដៃ និងគ្រឿងអេឡិចត្រូនិកដទៃទៀត ចូលក្នុងបន្ទប់ប្រឡងឡើយ។ ក្នុងករណីមានសម្ភារៈ ទាំងនេះនៅជាប់នឹងខ្លួន ត្រូវប្រគល់ជូនសមត្ថកិច្ចនៅក្រៅបន្ទប់ប្រឡង ឬអនុរក្សនៅតាមបន្ទប់រក្សាទុកជូន (មានផ្លាកលេខសម្រាប់ចំណាំ)។
- ត្រូវយកមកជាមួយនូវបង្កាន់ដៃទទួលពាក្យប្រឡងដែលមានបិទរូបថតសម្គាល់ខ្លួន ដើម្បីបង្ហាញជូនអនុរក្សដោយមានការផ្ទៀងផ្ទាត់ឈ្មោះនៅមុនពេលដើរចូលក្នុងបន្ទប់ប្រឡង។
- ត្រូវអង្គុយឲ្យចំលេខតុ ដែលបានកំណត់ និងរក្សាភាពស្ងៀមស្ងាត់។
- មិនអនុញ្ញាតឲ្យចូលប្រឡង ចំពោះបេក្ខជនដែលមកដល់បន្ទប់ប្រឡង ក្រោយការចាប់ផ្តើមចេញវិញ្ញាសារយៈពេល ១៥នាទី។
- ត្រូវសរសេរបំពេញឲ្យបានពេញលេញ និងត្រឹមត្រូវនៅលើក្បាលសន្លឹកកិច្ចការប្រឡង រួមទាំងឈ្មោះបេក្ខជន លេខតុ ឈ្មោះបន្ទប់ ឈ្មោះមណ្ឌលប្រឡង និងប្រភេទវិញ្ញាសាប្រឡង។
- មិនត្រូវប្តូរសន្លឹកកិច្ចការប្រឡង ឬក្រដាសព្រាង ឬផ្ទៀងផ្ទាត់ចម្លើយ ឬប្តូរចម្លើយ និងចម្លងចែកគ្នាឡើយ។ មិនត្រូវដាក់សន្លឹកកិច្ចការប្រឡងឆ្ងាយពីមុខរបស់ខ្លួន ផ្តល់លទ្ធភាពឲ្យអ្នកដទៃមើល ឬអាចយកទៅចម្លងបន្តបាន។

- មិនត្រូវធ្វើសញ្ញាសម្គាល់ ឬសញ្ញាផ្សេងៗ លើសន្លឹកកិច្ចការប្រឡងរបស់ខ្លួនឡើយ។ ក្នុងករណីរកឃើញថា បេក្ខជនណាម្នាក់ធ្វើសញ្ញាសម្គាល់ផ្ទុយពីបម្រាមនេះនឹងត្រូវលុបឈ្មោះចោលពីបញ្ជីប្រឡង និងបញ្ជីកំណែ។
- មិនត្រូវឲ្យអ្នកដទៃសរសេរជំនួស ឬមកប្រឡងជំនួសឡើយ។ ក្នុងករណីឃើញថា បេក្ខជនរូបណាបានធ្វើដូចនេះនឹងត្រូវលុបឈ្មោះចោលពីបញ្ជីប្រឡងភ្លាម។ បេក្ខជនរូបនេះ នឹងពុំត្រូវអនុញ្ញាតឲ្យចុះឈ្មោះក្នុងបញ្ជីប្រឡងនៅឆ្នាំបន្ទាប់ទៀតឡើយ។
- រាល់សន្លឹកកិច្ចការប្រឡង មិនអនុញ្ញាតឲ្យបោះចោលឡើយ ទោះបីសរសេរខុស។ បេក្ខជនអាចស្នើសុំសន្លឹកកិច្ចការប្រឡងបន្ថែមបាន បើសិនចាំបាច់។ ត្រូវប្រគល់គ្រប់សន្លឹកកិច្ចការប្រឡងទាំងអស់ជូនដល់អនុរក្ស នៅពេលដល់ម៉ោងប្រមូលកិច្ចការប្រឡង ទោះកិច្ចការ នោះបានធ្វើ ឬធ្វើពុំទាន់បានចប់សព្វគ្រប់ក៏ដោយ។ ក្នុងខណៈនេះ បេក្ខជនត្រូវសហការជាមួយអនុរក្សតាមបន្ទប់ពិនិត្យឡើងវិញ ក្នុងការបំពេញឈ្មោះ លេខតុ ឈ្មោះបន្ទប់ និងសំណៅចាំបាច់ផ្សេងទៀតនៃក្បាលសន្លឹកកិច្ចការប្រឡងជៀសវាងភាពខ្វះចន្លោះ។
- ពេលមានធុរៈចេញទៅក្រៅបន្ទប់ប្រឡងក្នុងពេលដែលកំពុងប្រឡង ឧទាហរណ៍ ដូចជាទៅបន្ទប់ទឹក បេក្ខជនត្រូវសុំការអនុញ្ញាតពីអនុរក្សជាមុនសិន និងមិនត្រូវចេញទៅលើសពីរយៈពេល ៥នាទីឡើយ។ ករណីបេក្ខជនមានជម្ងឺមិនអាចប្រឡងបាន គឺនឹងត្រូវបាត់បង់សិទ្ធិប្រឡងលើវិញ្ញាសានោះ។

**បទបញ្ញត្តិពិសេស**

អនុរក្ស ឬគណៈកម្មការប្រឡង មានសិទ្ធិបញ្ឈប់មិនឲ្យបេក្ខជនរូបណាមួយប្រឡងបន្តទៀតក្នុងករណីដែលបេក្ខជនរូបនោះ បានប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងនេះ និងទទួលការព្រមានចំនួនមួយលើករួចហើយ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**គឹម ទូច**

ចម្លងជូន ៖

- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
  *"ដើម្បីជូនជ្រាប"*
- គណៈកម្មការ, អនុគណៈកម្មការប្រឡង *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ